# Long Beach Unified School District

## មណ្ឌលអប់រំ ឡុងប៊ីច

**Hi Hill នៅ YMCA Camp Oakes**

## សៀវភៅព័ត៌មានសំរាប់គ្រួសារ

កម្មវិធីសិក្សាផ្នែកខាងក្រៅសំរាប់ថ្នាក់ទី៥

YMCA Camp Oakes

Big Bear City, CA

# តារាងមាតិកា


លិខិតពីអគ្គនាយក.........................................................................................3

សេចក្តីសង្ខេបអំពីដំណើរការសិក្សាទៅកាន់ Hi Hill នៅ Camp Oakes .................................................... 4

ព័ត៌មានទូទៅអំពី Hi Hill នៅ Camp Oakes............................................................................... 5-7

គោលការណ៍ច្បាប់ និង នីតិវិធី LBUSD សំរាប់ Camp Oakes..............................................8-10

បញ្ជីត្រួតពិនិត្យ មុននឹងចេញដំណើរ...........................................................................11-13

Office of the Superintendent
1515 Hughes Way, Long Beach, CA 90810
(562) 997-8242

ខែឧសភា 2023

ជូនចំពោះក្រុមគ្រួសារនៃសិស្សថ្នាក់បឋមសិក្សា និង K-8 ជាទីគោរព

ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមជំរាបជូនលោកអ្នកថា ជាផ្នែកមួយនៃកម្មវិធីសិក្សារបស់មណ្ឌលអប់រំ ឡុងប៊ីច គឺសិស្សរៀនថ្នាក់ទី ប្រាំ ទាំងអស់នឹងមានឱកាសចូលរួមពេញមួយសប្តាហ៍ក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅ (Outdoor Education) នៅ Camp Oakes ដែលស្ថិតនៅក្បែរក្រុង Big Bear នៃរដ្ឋកាលីហ្វ័រញ៉ា ចាប់ផ្តើមក្នុងរដូវស្លឹកឈើជ្រុះ នៃឆ្នាំ2023 ។ ការធ្វើដំណើរសិក្សាទាំងអស់នេះនឹងបន្តធ្វើតាមទំលាប់ពីមុនមក ដែលបានចាប់ផ្តើមឡើងនៅក្នុងមណ្ឌលអប់រំរបស់យើងក្នុងខែមេសា នៃឆ្នាំ1948 ដែលមានសិស្សទៅចូលរួម Camp Hi-Hill ជារៀងរាល់ឆ្នាំ ។ គួរអោយស្តាយ ដោយមូលហេតុថា ក្នុងឆ្នាំ2010 គឺកម្មវិធីសិក្សាផ្នែកខាងក្រៅត្រូវបានបិទចោល ។ ខ្ញុំមាន សេចក្តីរីករាយ ដែលគណៈកម្មការអប់រំរបស់យើងបានធ្វើការអនុម័តក្នុងពេលថ្មីៗនេះក្នុងការបង្កើតឡើងវិញនូវកម្មវិធីសិក្សាផ្នែកខាងក្រៅនៅ Camp Oakes តាមរយៈប្រើសេវាដ្ឋានរបស់ YMCA ។

ការរៀបចំសំរាប់ដំណើរសិក្សាផ្នែកខាងក្រៅនេះ ដោយរាប់បញ្ចូលទាំងការដឹកជញ្ជូនតាមឡាន ប៊ីស នឹងត្រូវចាត់ចែងនិងឧបត្ថមដោយក្រសួងថ្នាក់លើ ។ ប៉ុន្តែលោកអ្នក នឹងមានការស្នើសុំអោយផ្តល់ជាព័ត៌មានចុះឈ្មោះដ៏ចាំបាច់ ដើម្បីធានាអោយមានការរៀបចំដំណើរអោយបានត្រឹមត្រូវសំរាប់សិស្សរបស់លោកអ្នក ។ សាលារៀននីមួយៗ នឹងចាកចេញដំណើរខុសថ្ងៃខែពីគ្នានៅទូទាំងឆ្នាំសិក្សា ហើយដូច្នេះ <u>សៀវភៅដៃ Camp Oakes សំរាប់គ្រួសារ</u> ត្រូវបានរៀបចំឡើងដើម្បីអោយប្រាកដថា ការទៅលេងដល់កន្លែងផ្ទាល់ គឺនឹងនាំមកជាបទពិសោធន៍ដ៏ល្អសំរាប់សិស្ស គ្រូបង្រៀន និងបុគ្គលិក LBUSD ដែលទៅចូលរួម ។ ដោយមានការជ្រោមជ្រែងពីលោកអ្នក គឺខ្ញុំជឿជាក់ថា ការធ្វើដំណើរពេញមួយសប្តាហ៍ទៅកាន់ភ្នំនឹងនៅតែបន្តជាការផ្តល់នូវបទពិសោធន៍ដ៏មានអត្ថន័យសំរាប់សិស្សថ្នាក់ទីប្រាំ របស់យើង ដែលនឹងលើកកម្ពស់នូវចំណេះផ្នែកធម្មជាតិ និងវិទ្យាសាស្ត្រ ព្រមទាំងជួយពួកគេផងដែរក្នុងបង្កើននូវទំនាក់ទំនង និងជំរៅទឹកចិត្តខ្ពស់ ចំពោះខ្លួនផ្ទាល់ ។

បើលោកអ្នកមានសំនួរ ឬ ក្តីកង្វល់អ្វី គឺសូមទាក់ទងតាមទូរស័ព្ទ ឬ អ៊ីមែលទៅកាន់លោក Jeff Wood, នាយកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកខាងក្រៅ ដែលលោកធ្វើការនៅការិយាល័យកម្មវិធីសិក្សាសំរាប់កុមារតូចៗ និងកំរិតថ្នាក់បឋមសិក្សា តាមរយៈលេខ (562) 997-8247 ឬ jwood@lbschools.net ។

ដោយសេចក្តីស្មោះ

Jill A. Baker, Ed.D
អគ្គនាយក

## Hi Hill នៅ Camp Oakes

# សេចក្តីសង្ខេបអំពីការធ្វើដំណើរសិក្សា

## <u>គោលដៅ</u>

ការធ្វើដំណើរសិក្សាសំរាប់សិស្សថ្នាក់ទី ប្រាំ ទៅកាន់ Hi Hill នៅ Camp Oakes ត្រូវបានធ្វើតាមគំរោងដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់មណ្ឌលអប់រំឡុងប៊ីច ដើម្បីជួយយុវវ័យអោយទទួលបាននូវឱកាសប្រកបដោយសមធម៌សំរាប់ស្វែងយល់អំពីពិភពផ្សេង ក្រៅតែពីសហគមន៍របស់ពួកគេ ។ ឱកាសនេះផ្តល់ជាឱកាសសំរាប់សិស្សថ្នាក់ទី ប្រាំ ម្នាក់ៗអោយរស់នៅ និងសិក្សាអំពីផ្នែកខាងក្រៅក្នុងរយៈពេលមួយសប្តាហ៍ ។ ការស្រាវជ្រាវបានបញ្ជាក់ថា កម្មវិធីសិក្សាផ្នែកខាងក្រៅនាំមកជាប្រយោជន៍ច្រើនចំណែកណាស់ ។ វាអាចជួយ**បង្កើននូវជំនឿទុកចិត្តចំពោះខ្លួន ជំរើទឹកចិត្តក្នុងខ្លួន ជំនាញផ្នែកទំនាក់ទំនង ការនិយាយស្តី ទឹកចិត្តប្រឹងប្រែង និងជំនាញបញ្ចេញកំលាំងកាយ** សំរាប់ទ្រទ្រង់អាកប្បកិរិយាល្អ ដើម្បីឈានឆ្ពោះទៅកាន់ការសិក្សា និងការពង្រីកនូវសមត្ថភាពរបស់ខ្លួនសំរាប់បំពេញកិច្ចកាដ៏មានការសហការណ៍ ។

## <u>តើសិស្សនឹងសិក្សាអំពីអ្វី</u>

Hi Hill នៅ YMCA Camp Oakes ផ្តល់ជាឱកាសសិក្សាពិសេសសំរាប់កុមារអោយជួប និងធ្វើការចុះសំរុងជាមួយមនុស្សមកពីមជ្ឈដ្ឋានផ្សេងៗ ដែលនឹងបានជាប្រយោជន៍សំរាប់ពួកគេនៅតាមសាលារៀន និងក្នុងទូទាំងជីវិតរបស់ពួកគេ ។ ការរស់នៅតាមបរិស្ថានសិក្សារយៈពេល 24 ម៉ោងក្នុងមួយថ្ងៃ គឺសិស្សនឹងមានឱកាសបង្កើននូវការយល់ដឹង និងការបណ្តុះនូវទឹកចិត្តនៃគោលដៅតាមរយៈស្ថានការជីវិតជាក់ស្តែង ។ នៅតាម Hi Hill នៅ YMCA Camp Oakes គឺសិស្សមានមុខងារទទួលខុសត្រូវថ្មី ចេះគោរព និងទទួលស្គាល់មិត្តភាពរបស់មិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេតាមរយៈបទពិសោធន៍ផ្សេងៗជាសោភណភាព និងអ្វីផ្សេងៗដ៏អស្ចារ្យនៃផ្នែកធម្មជាតិខាងក្រៅ ។ សិស្សនឹងហាត់ប្រើជំនាញផ្នែកទំនាក់ទំនង ការគ្រប់គ្រងចំពោះខ្លួនឯង និងបង្កើនភាពលូតលាស់ផ្នែកផ្នត់គំនិតរបស់ពួកគេតាមរយៈការរស់នៅប្រចាំថ្ងៃ ដោយមានការយកចិត្តទុកដាក់ចំពោះមនុស្សដទៃ និងការថែទាំចំពោះខ្លួនរបស់ពួកគេផ្ទាល់ ។

នៅក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅ គឺសិស្សរៀនយល់ផ្ទាល់តែម្តងអំពីគោលគំនិតផ្នែកវិទ្យាសាស្ត្រ ដូចជា៖ ទេសភាព រុក្ខជាតិ និងសត្វព្រៃ ភូគព្ភសាស្ត្រ ថ្ម និងរ៉ែ ហ្វូងផ្កាយ រុក្ខសាស្ត្រ អាកាសធាតុ ប្រព័ន្ធទឹក និងអ្វីផ្សេងៗទៀតទាក់ទងផ្នែកវិទ្យាសាស្ត្រ ព្រមទាំងជំនាញផ្នែកទំនាក់ទំនងផងតាមរយៈការទទួលឱកាសសិក្សាជារបៀបដកពិសោធន៍ផ្ទាល់ ។ កម្មវិធីសិក្សា ដែលត្រូវបានលើកបង្ហាត់ គឺជាចំណែកសំខាន់មួយនៃបទពិសោធន៍សិក្សាផ្នែកវិទ្យាសាស្ត្រនៃសិស្សរបស់លោកអ្នក ។ កម្មវិធីសិក្សាផ្នែកខាងក្រៅនាំយកសិស្សចេញពីបន្ទប់រៀនទៅកាន់បន្ទប់រៀនប្លែកៗដែលសិស្សសិក្សាដោយអនុវត្ត និងទទួលបទពិសោធន៍ផ្ទាល់ដៃ ។ កម្មវិធីសិក្សាផ្នែកខាងក្រៅផ្តល់បទពិសោធន៍ផ្នែកសិក្សាដ៏រំភើប និងរីករាយសំរាប់សិស្ស ។ ដោយមូលហេតុនេះ សិស្សសិក្សាកាន់តែលឿន យល់ដឹងកាន់តែច្បាស់ និងចងចាំបានកាន់តែច្រើនអំពីអ្វីដែលពួកគេសិក្សា ។

នៅតាម Hi Hill នៅ YMCA Camp Oakes គឺមានសកម្មភាពជាច្រើនសំរាប់សិស្ស ដែលរាប់បញ្ចូលដូចជា៖ បាញ់ធ្នូ គំនូរ និងសិប្បកម្ម ស្ទូចត្រី ល្បែងជាក្រុម ហ្វ្រិហ្វ ឌិស្ក លេងបាល់ទះ ការស្រាវជ្រាវរុករកធម្មជាតិ ដំណើរកំសាន្តកាត់ព្រៃភ្នំ ជិះទូកកានូ លេងបាល់ ហ្គា តោងឡើងថ្ម លោតអន្ទាក់ ការអង្កេតនិងសម្លឹងមើលហ្វូងផ្កាយ កម្មវិធីជួបជុំគ្នាក្បែរភ្នក់ភ្លើង អមដោយការច្រៀង និងការសើចសប្បាយជាមួយរឿងកំប្លែងខ្លីៗ រួមទាំងសកម្មភាពជាច្រើនផ្សេងទៀត ។ ទាំងអស់នេះនឹងជួយសិស្សបង្កើនចំណេះរបស់ពួកគេ ជំរុញពួកគេអោយចេះធ្វើការតស៊ូ និងបំពេញកិច្ចការរួមគ្នាក្នុងការសិក្សាអំពីធម្មជាតិផ្នែកខាងក្រៅ ។

មានឪពុកម្តាយ និងជីដូនជីតាជាច្រើន ដែលបានរៀននៅតាមសាលាបឋមសិក្សាក្នុង LBUSD នៅតែនឹកចងចាំយ៉ាងច្បាស់លាស់អំពីការចំណាយពេលពេញមួយសប្តាហ៍របស់ពួកគេជាមួយកម្មវិធីសិក្សាផ្នែកខាងក្រៅ ហើយយើងដឹងថា សិស្សរបស់លោកអ្នកក៏នឹងនឹកឃើញដូច្នោះដែរ ។

# Hi Hill នៅ YMCA Camp Oakes

# ព័ត៌មានទូទៅ

## **ទីតាំងសេវាដ្ឋាន**

កម្មវិធីសិក្សាផ្នែកខាងក្រៅរបស់មណ្ឌលអប់រំ ឡុងប៊ីច ស្ថិតនៅ Long Beach YMCA's Camp Oakes លើខ្នងភ្នំ San Bernardino ក្បែរក្រុង Big Bear ។ មានទីតាំងស្ថិតនៅលើផ្ទៃដីប្រមាណ 235 អេកឺ ក្នុងឧទ្យានជាតិ San Bernardino National Forest ដែលមានកំពស់ 7,200 ហ្វីត ។ Camp Oakes មានចម្ងាយប្រមាណ 120 ម៉ៃ ពីក្រុង Long Beach ឬ 15 នាទី ពីក្រុង Big Bear ។

## **ការចំណាយ**

Hi Hill នៅ YMCA Camp Oakes នឹងមានការបង់ថ្លៃចំណាយទាំងស្រុងដោយមណ្ឌលអប់រំ ឡុងប៊ីច ។ គ្មានត្រូវបង់ថ្លៃអ្វីឡើយសំរាប់ទៅចូលរួម ។ ក្រុមគ្រួសារទទួលខុសត្រូវក្នុងការផ្តល់សំលៀកបំពាក់ និងប្រដាប់ប្រដារគេងត្រឹមត្រូវសំរាប់សិស្សរបស់ពួកគេ ។ ក្រុមគ្រួសារទាំងឡាយណាដែលត្រូវការសំលៀកបំពាក់ ឬប្រដាប់ប្រដារគេង គឺគួរទាក់ទងទៅកាន់លោក Jeff Wood ជានាយកគ្រប់គ្រងកម្មវិធីសិក្សាផ្នែកខាងក្រៅប្រចាំ LBUSD នៅតាម jwood@lbschools.net ឬ នាយកនៅតាមសាលារៀនរបស់ពួកគេ ដើម្បីពិគ្រោះអំពីសេចក្តីត្រូវការរបស់ពួកគេ ។

## **ការដឹកជញ្ជូន**

មណ្ឌលអប់រំ ឡុងប៊ីច នឹងផ្តល់នូវការដឹកជញ្ជូនតាមឡាន ប៊ីស ទៅមកពី Hi Hill នៅ YMCA Camp Oakes នៅចំថ្ងៃត្រូវចេញដំណើរ និងថ្ងៃត្រឡប់មកវិញ ដោយគ្មានទាមទារថ្លៃបង់ចំណាយឡើយ ។ បើមានមូលហេតុណាមួយដែលតំរូវអោយសិស្សត្រឡប់ទៅផ្ទះវិញក្នុងសប្តាហ៍ដែលកំពុងចូលរួមកម្មវិធីសិក្សាផ្នែកខាងក្រៅនេះ គឺប្រហែលជាតំរូវអោយមាតាបិតាទៅទទួលយកសិស្សចេញពីកម្មវិធីមកផ្ទះវិញ ដោយចេញបង់ថ្លៃចំណាយដោយខ្លួនឯង ។

## **ទទួលស្គាល់ជាផ្លូវការនៃកម្មវិធីសិក្សាផ្នែកខាងក្រៅ**

YMCA Camp Oakes មានការទទួលស្គាល់ជាផ្លូវការដោយ American Camp Association ដែលមានន័យថា វាជាកន្លែងធ្លាប់បានទទួលការពិនិត្យវាយតំលៃ ដើម្បីរៀបចំអោយស្របស្តង់ដាផ្នែកសុខភាព និងសុវត្ថិភាពជាង 300 ផ្នែក ដែលរៀបចំចងក្រងដោយអ្នកជំនាញការមកពីវិស័យជាច្រើនដូចជា៖ ការគ្រប់គ្រងផ្នែកហានិភ័យ ការបណ្តុះបណ្តាលកុមារ ជលជាតិ និងសុខុមាលភាព ។ ក្រសួងសុខាភិបាលប្រចាំ San Bernardino ខោនធី និងការិយាល័យផ្សេងៗរបស់ ខោនធី/រដ្ឋ ក៏បានធ្វើការត្រួតពិនិត្យមើលកន្លែងសំរាប់កម្មវិធីសិក្សាផ្នែកខាងក្រៅនោះផងដែរ ស្របតាមការចែងតំរូវ ។

## **ការស្នាក់នៅ**

គ្រូៗរបស់សិស្សទាំងអស់ នឹងបង្កើតជាក្រុមរួមគ្នាត្រឹមត្រូវតាមភេទ មុននឹងដល់ពេលចេញដំណើរ ។ គ្រូនឹងព្យាយាមអោយអស់ពីសមត្ថភាព ដើម្បីរាប់បញ្ចូលយ៉ាងតិចអោយមានមិត្តម្នាក់របស់សិស្សសំរាប់ស្នាក់នៅរួមគ្នា ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏មិនមានការអះអាងឡើយថា មិត្តទាំងអស់នឹងនៅជុំគ្នា ។ កន្លែងស្នាក់នៅនឹងមានសិស្សមកពីថ្នាក់រៀនផ្សេងៗ ឬ មកពីសាលារៀនផ្សេងៗក្នុង LBUSD ដែលទៅចូលរួមដែរក្នុងសប្តាហ៍ជាមួយគ្នា ដើម្បីផ្តល់នូវឱកាសសំរាប់ការរាប់អានមិត្តថ្មី ។

## **ការត្រួតត្រាមើលក្នុងកន្លែងស្នាក់នៅ**

**ក្រុមទាំងអស់នៅតាមកន្លែងស្នាក់នៅនឹងមានការត្រួតត្រាមើលដោយមនុស្សធំជាអ្នកផ្តល់ឱវាទ ។ ធម្មតា ក្នុងចំណោមក្រុមសិស្ស ប្រាំបីនាក់ គឺមានមនុស្សធំម្នាក់ ។ បុគ្គលិកទាំងអស់ត្រូវបានធ្វើការជ្រើសរើស ដោយមូលហេតុថា ពួកគេមានសមត្ថភាពធ្វើកិច្ចការជាមួយកុមារ និងធ្លាប់ទទួលការហ្វឹកហ្វឺនជាច្រើនលើក មុននឹងដល់ពេលសប្តាហ៍កម្មវិធីសិក្សាផ្នែកខាងក្រៅ ។ បុគ្គលិកគ្រប់គ្រងមានសមត្ថភាព ដោយមានបទពិសោធន៍យូរឆ្នាំអំពីការធ្វើកិច្ចការជាមួយកុមារក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។ បុគ្គលិក YMCA Camp Oakes និងបុគ្គលិក LBUSD ទាំងអស់ត្រូវបានទទួលការចែងតំរូវអោយធ្វើការរាយប្រាប់អំពីអំពើសង្ស័យរំលោភសិទ្ធិកុមារ (រាប់ទាំងផ្នែករូបកាយ ផ្លូវចិត្ត ពាក្យសំដី និង/ឬ ការធ្វេសប្រហែស) ទៅកាន់អាជ្ញាធរជាបន្ទាន់ ។**

## ជំងឺនឹកផ្ទះ

ការនៅដាច់ឆ្ងាយពីផ្ទះអស់រយៈពេលមួយសប្តាហ៍អាចក្លាយជាបទពិសោធន៍លំបាកម្យ៉ាងសំរាប់កុមារគ្រប់វ័យទាំងអស់ ។ នៅពេលកុមារស្ថិតនៅឆ្ងាយពីផ្ទះជាលើកដំបូង ពួកគេប្រហែលជានឹកផ្ទះ ។ យើងស្នើសុំអោយលោកអ្នកជួយពន្យល់កូន មុននឹងពេលចេញដំណើរ ។ និយាយប្រាប់ពួកគេថា លោកអ្នកមានការទុកចិត្តថា ពួកគេនឹងអាចដោះស្រាយបានអំពីបទពិសោធន៍ថ្មីៗក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។ ធ្វើការសង្កត់មកលើតែអ្វីជាចំណែកល្អៗ មិត្តថ្មីៗ សកម្មភាពដែលពួកគេនឹងចូលរួមសប្បាយ និងការកោតសរសើរពីលោកអ្នកនៅពេលពួកគេបានទទួលជោគជ័យ ។ នៅពេលធ្វើដំណើរទៅដល់កន្លែងហើយ បុគ្គលិកនឹងប្រើមធ្យោបាយដ៏ពិសេសៗសំរាប់ជួយសំរាលបញ្ហានឹកផ្ទះ – ដោយធ្វើអោយសិស្សមានការមមាញឹកនិងសប្បាយៗ ។ យើងសុំអោយមានការសរសេរសំបុត្រផ្ញើមកពីផ្ទះ ។ សំបុត្រលើកទឹកចិត្តផ្ញើមកពីផ្ទះនឹងធ្វើអោយសិស្សរបស់លោកអ្នកទទួលដឹងអំពីអ្នកតាមមធ្យោបាយដែលមានការលើកទឹកចិត្តក្នុងការកែលម្អ ។ សូមចងចាំថា Camp Oakes បាននាំមកជាបទពិសោធន៍ដ៏ល្អៗទៅកាន់សិស្សរាប់ពាន់នាក់អស់ជាច្រើនឆ្នាំកន្លងមក ហើយយើងដឹងថា ហើយវានឹងផ្តល់បទពិសោធន៍ដូច្នោះដែរសំរាប់សិស្សរបស់លោកអ្នក ។

## ការត្រៀមរៀបចំទុកសំរាប់ដំណើរសិក្សា

កម្មវិធីសិក្សាផ្នែកខាងក្រៅ គឺជាកន្លែងសប្បាយ និងជាឱកាសសំរាប់សិស្សរបស់លោកអ្នកកសាងជំរៅទឹកចិត្ត និងបង្កើតនូវជំនាញផ្នែកទំនាក់ទំនង ។ នេះក៏ជាឱកាសផងដែរសំរាប់រៀនអំពីឯករាជភាព និងកិច្ចការទទួលខុសត្រូវ ។ សិស្សនឹងថែទាំខ្លួន រៀបចំគ្រែ និងថែរក្សាអីវ៉ាន់របស់ខ្លួន ។ នៅផ្ទះ គឺយើងស្នើសុំអោយមាតាបិតាធ្វើការបណ្តោយអោយសិស្សរៀបចំអីវ៉ាន់ដោយខ្លួនគេ និងវេចខ្ចប់តាមរយៈប្រើ***<u>បញ្ជីត្រួតពិនិត្យសំរាប់សិស្ស មុននឹងចេញដំណើរ</u>*** ។ ការធ្វើដូច្នេះ សិស្សរបស់លោកអ្នករៀនអំពីរបៀបចាត់ចែងដោយខ្លួនគេ និងវាជួយធ្វើអោយគេមានទឹកចិត្តសប្បាយអំពីការចេញដំណើរ ។ សិស្សមិនអាចខ្ចប់យកចំណី និង/ឬ គ្រាប់ស្ករទៅជាមួយបានទេ ។ សូមមានការជ្រោមជ្រែង និងផ្តោតទៅលើលទ្ធផលថ្មីៗនិងល្អៗ ដែលនឹងកើតមានឡើង ។ សូមអោយប្រាកដថា លោកអ្នក និងសិស្សយកចិត្តទុកដាក់ទៅលើរបស់ប្រើប្រាស់អ្វី ដែល*<u>មិន</u>*អាចយកទៅកាន់ Camp Oakes ជាមួយបាន៖

**របស់ប្រើប្រាស់មិនអាចយកទៅបាន - <u>កុំយកទៅជាមួយ!</u>**

- គ្រឿង អេឡិចត្រូនិច **<u>គ្រប់ប្រភេទ</u>** ដូចជា៖
  - ទូរស័ព្ទដៃ ឬ ឧបករណ៍ធ្វើទំនាក់ទំនងផ្សេងៗ
  - ឡេបថប ថេប្លិត iPod, Earbuds ឬ នាឡិកា Smart Watch
  - ឧបករណ៍ ហ្គេម សំរាប់កាន់លេង
- ដែកកេះ ឬ កាំជ្រួច
- កាំបិត ឬ កូនពូថៅដៃ
- កាំភ្លើង
- គ្រឿងថ្នាំជក់
- គ្រឿងថ្នាំខុសច្បាប់
- ចំណី
- ស្ករទំពារ ឬ គ្រាប់ស្ករ
- ថ្នាំបាញ់សំអាតក្លិន (បំបាត់ក្លិន)

ចំពោះរបស់ប្រើប្រាស់ទាំងឡាយណា ដែលមិនត្រូវនាំយកទៅជាមួយ គឺនឹងត្រូវដកហូតទុក ដោយសរសេរឈ្មោះនៃសិស្សរបស់លោកអ្នកនៅពីលើ និងរក្សាទុកនៅក្នុងការិយាល័យ ទំរាំតែដល់ថ្ងៃចេញដំណើរត្រឡប់ទៅផ្ទះវិញ ។ របស់ដកហូតទុក គឺនឹងប្រគល់ទៅកាន់សិស្សវិញ ស្របពេលត្រឹមត្រូវក្នុងកន្លែងដែលក្រុមគ្រួសារទៅទទួលយកសិស្ស ។ LBUSD និង/ឬ YMCA គ្មានការទទួលខុសត្រូវអ្វីទេចំពោះរបស់ប្រើប្រាស់ ដែលបានបាត់បង់ ឬ បាក់បែកក្នុងពេលដំណើរការនេះ ។

# ព័ត៌មានទាក់ទងសំរាប់ Hi Hill នៅ YMCA Camp Oakes

## <u>មធ្យោបាយទាក់ទងជាមួយសិស្សរបស់លោកអ្នក</u>

គ្រួសារ គឺត្រូវស្វាគមន៍អោយសរសេរផ្ញើសំបុត្រទៅសួរសុខទុក្ខសិស្ស នៅពេលពួកគេកំពុងស្នាក់នៅនិងចូលរួមក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។ សិស្សសប្បាយចិត្តនឹងបានសំបុត្រសួរសុខទុក្ខ ។ ប៉ុន្តែ សូមមេត្តាកុំរៀបរាប់អំពីបញ្ហាក្នុងផ្ទះ ឬ ការនឹករលឹកដល់សិស្សពីអ្នកផ្ទះអោយសោះ ។ សូមប្រកាន់យកទឹកចិត្តល្អៗ ។ សូមផ្ញើសំបុត្រទៅមុននឹងដល់ថ្ងៃចេញដំណើរ ដើម្បីអោយប្រាកដថា សិស្សរបស់លោកអ្នកពិតជាបានទទួលសំបុត្រនៅក្នុងសប្តាហ៍នោះ ។ ការផ្ញើសំបុត្រ ឬ ប៉ូស្តកាដ ដោយមានស្តែមនិងអាស័យដ្ឋានអ្នកទទួលដែលរៀបចំទុកជាមុន គឺបង្កើនឱកាសសំរាប់សិស្សរបស់លោកអ្នកក្នុងការទទួលបានសំបុត្រនោះ ។ សូមចំណាំថា ពេលវេលានៅឯ Camp Oakes ដើរយឺតជាងពេលវេលានៅតាមទីក្រុង ។ ដូច្នេះ សូមទុកពេល 4 ថ្ងៃសំរាប់ការផ្ញើសំបុត្រទៅនិងមកពីផ្ទះ ។ <u>**សូមកុំ**</u> ផ្ញើកញ្ចប់ដែលមានអាហារ ឬ គ្រាប់ស្ករ ទៅជាមួយអោយសោះ ។ Camp Oakes ស្ថិតនៅលើភ្នំ ហើយអាហារគឺធុំក្លិននិងធ្វើអោយសត្វល្អិតៗ និងសត្វធំៗចង់មករកស៊ីចំណី ។

មាតាបិតាក៏អាចសរសេរសំបុត្រសួរសុខទុកផងដែរ និងប្រគល់អោយគ្រូប្រង្វៀនប្រចាំថ្នាក់ មុននឹងដល់ថ្ងៃចេញដំណើរ ។ គ្រូបង្រៀន នឹងចែកសំបុត្រអោយសិស្សក្នុងពេលទទួលអាហារនៅឯកម្មវិធីសិក្សាផ្នែកខាងក្រៅ ។

សូមផ្ញើសំបុត្រទៅកាន់អាស័យឋានដូចតទៅ៖

### <u>បើប្រើតាម ប្រៃសណីយ៍</u>៖

*YMCA Camp Oakes*
*ឈ្មោះរបស់សិស្សនិងថ្ងៃខែស្នាក់នៅ Camp*
*P.O. Box 452*
*Big Bear City, CA 92314*

### <u>បើប្រើតាម UPS ឬ Fed Ex</u>:

*YMCA Camp Oakes*
*ឈ្មោះរបស់សិស្សនិងថ្ងៃខែស្នាក់នៅ Camp*
*47400 Monte Vista Drive*
*Big Bear City, CA 92314*

# គោលការណ៍ច្បាប់ និង នីតិវិធីរបស់ Hi Hill នៅ YMCA Camp Oakes

## ការប្រើថ្នាំពេទ្យ

សូមកុំដាក់ថ្នាំពេទ្យអ្វីទៅក្នុងវ៉ាលីសនៃសិស្សរបស់លោកអ្នកអោយសោះ រួមទាំងថ្នាំទិញដែលមិនមានវេជ្ជបញ្ជា ។ ថ្នាំពេទ្យទាំងអស់គឺត្រូវតែប្រគល់អោយអ្នកគ្រូពេទ្យនៅពេលព្រឹកនៃថ្ងៃចេញដំណើរ ។ អ្នកគ្រូពេទ្យនឹងពិនិត្យមើលថ្នាំទាំងអស់ និងកត់ទុកក្នុងបញ្ជី អនឡាញ ។ បើសិស្សរបស់លោកអ្នកត្រូវការប្រើថ្នាំពេទ្យនៅថ្ងៃចេញដំណើរ សូមលោកអ្នករក្សាទុកជា ដូស នៅក្នុងស្រោមសំបុត្រ ដោយដាក់ឈ្មោះសិស្សរបស់លោកអ្នក រួមទាំងឈ្មោះថ្នាំនិងម៉ោងដែលត្រូវប្រើ ហើយប្រគល់ជូនទៅអ្នកគ្រូពេទ្យ ។ ថ្នាំពេទ្យចេញពីវេជ្ជបណ្ឌិតត្រូវតែមាននៅក្នុងដបរបស់ឱសថស្ថានត្រឹមត្រូវ ដោយមានឈ្មោះសិស្សរបស់លោកអ្នកដាក់លើដប រួមទាំងការណែនាំអំពីរបៀបប្រើពីវេជ្ជបណ្ឌិតផងដែរ ។ ចំពោះថ្នាំដែលទិញដោយមិនបាច់មានវេជ្ជបញ្ជា គឺត្រូវទិញមកពីកន្លែងត្រឹមត្រូវ ដោយមានសរសេរឈ្មោះសិស្សរបស់លោកអ្នកនៅលើដបនោះ ។ <u>ថ្នាំផ្សេងៗ (រាប់ទាំងថ្នាំបំប៉ន វីតាមីន) គឺមិនអាចនាំយកទៅជាមួយបានទេ</u> - អ្នកគ្រូពេទ្យនៅឯកម្មវិធីសិក្សាផ្នែកខាងក្រៅនឹងរៀបចំចាត់ចែងថ្នាំទាំងអស់ ។ សូមផ្តល់ថ្នាំគ្រប់ចំនួនដែលអាចប្រើបានសំរាប់រយៈពេល 10 ថ្ងៃ ដើម្បីអោយយើងមានការត្រៀមលក្ខណៈក្នុងករណីស្ថានការណាមួយដែលអាចកើតមានឡើងដោយមិនបានរំពឹងទុកជាមុន (ដូចជា៖ អាកាសធាតុមិនល្អ ជាដើម)

## ទូរស័ព្ទដៃ/ទំនាក់ទំនងជាមួយសិស្ស

សូមរក្សាទុកទូរស័ព្ទដៃ ថេប្លិត និងនាឡិកា smart watch នៅផ្ទះ ដោយឧបករណ៍ទាំងនេះគឺមិនត្រូវបានអនុញ្ញាតអោយសិស្សប្រើទេនៅឯ Camp Oakes ។ ក្រុមគ្រួសារ គឺត្រូវបានជំរុញលើកទឹកចិត្តអោយធ្វើការទាក់ទងតាមការផ្ញើសំបុត្រសួរសុខទុក្ខទៅកាន់សិស្សរបស់ពួកគេ ដូចដែលបានជំរាបជូនមុននេះរួចមកហើយ ។ ក្រុមគ្រួសារក៏អាចប្រគល់សំបុត្រសួរសុខទុក្ខសិស្សទៅគ្រូសំរាប់ទុកអោយសិស្សបានផង ក្រៃងលោសំបុត្រតាម ប៉ុស្ត ផ្ញើទៅដល់មិនទាន់ពេល ។ សូមមេត្តាកុំផ្ញើអាហារស្ករគ្រាប់ និងអ្វីផ្សេងៗទៀតដែលត្រូវហាមមិនអោយយកទៅជាមួយអោយសោះ ។

## ការថែទាំសុខភាព

សិស្ស ដែលមានជំងឺ គឺមិនអាចទៅចូលរួមក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅបានទេ ។ បើសិស្សទទួលជំងឺនៅឯ Camp Oakes គឺមានអ្នកគ្រូពេទ្យប្រចាំកន្លែងជួយមើលខុសត្រូវ ។ ក្នុងករណីដែលមានជំងឺ សិស្សនឹងទទួលការស្នាក់នៅក្នុងបន្ទប់ព្យាបាលសុខភាពក្នុងរយៈពេលចាំបាច់ដ៏សមហេតុផលមួយ ។ បើចាំបាច់ណាស់ គឺមាតាបិតា/អាណាព្យាបាលនឹងត្រូវបានទាក់ទងអោយទៅដកសិស្សរបស់ពួកគេចេញបាន ។ បើសិស្សរបស់លោកអ្នកមានជំងឺមុនពេលចេញដំណើរ គឺអ្នកគ្រូពេទ្យនឹងធ្វើការពិនិត្យអោយប្រាកដថា ពួកគេពិតជាមានសុខភាពមាំមួនគ្រប់គ្រាន់មែន ដើម្បីចូលរួមក្នុងការធ្វើដំណើរពេញមួយសប្តាហ៍នៅលើភ្នំដែលពោរពេញសកម្មភាពដ៏មមាញឹកនិងស្វាហាប់មែនទែន ។

ចំពោះសិស្សទាំងឡាយណា ដែលមានបញ្ហាសុខភាព ដូចជា៖ គ្រុនក្តៅចាប់ពី 100.4 អង្សា ឡើងទៅ ឈឺបំពងក ក្អួត រាគ រមាស់ស្បែកខ្លាំង ដំបៅស្នាម ឬ ជាំដោយសាររបួស និង/ឬ ចៃក្បាល (ពង ឬ ចៃរស់រវើក) គឺនឹងត្រូវដកឈ្មោះចេញពីការចូលរួម ដើម្បីការពារសុខភាពរបស់មនុស្សដទៃ ។

បើមានភាពអាសន្ន ឬ សេចក្តីត្រូវការពិសេសអ្វីមួយចាំបាច់កើតឡើង គឺយើងអាចស្វែងរកវេជ្ជបណ្ឌិត និងប្រើមន្ទីរ គ្លីននិក នៅ Big Bear បាន ។ បើមានការរងរបួសនៅកន្លែងផ្ទាល់ គឺយើងនឹងចាត់វិធានការចាំបាច់ ដើម្បីធ្វើការព្យាបាលអោយត្រឹមត្រូវ ដែលអាចមាន៖ ការព្យាបាលដោយបុគ្គលិកចំពោះរបួសតូចតាច ការទាក់ទងជាមួយមាតាបិតា/អាណាព្យាបាលសំរាប់ទទួលការបង្គាប់ណែនាំពីពួកគេ ការទាក់ទងទៅកាន់មន្ទីរព្យាបាលប្រចាំតំបន់ ឬ ការបញ្ជូនសិស្សអោយទៅទទួលការព្យាបាលដោយវេជ្ជបណ្ឌិត ឬ មន្ទីរព្យាបាល/សង្គ្រោះបន្ទាន់ ។ មាតាបិតានៃសិស្ស ដែលមានកំដៅក្នុងខ្លួនចាប់ពី 100.4 អង្សា ឡើងទៅ គឺនឹងទទួលការទាក់ទងហៅជួប និងប្រហែលជាត្រូវដកចេញពីកម្មវិធីផ្នែកខាងក្រៅទៀតផង ។

ជាការសំខាន់ណាស់ ដែលលោកអ្នកផ្តល់ព័ត៌មានយ៉ាងពេញលេញនិងត្រឹមត្រូវសំរាប់ងាយទាក់ទងក្នុងគ្រាអាសន្ន នៅពេលធ្វើការចុះឈ្មោះ ។ បើលោកអ្នកនឹងធ្វើដំណើរកំសាន្ត គឺសូមរាយបង្ហាញអំពីឈ្មោះកន្លែងត្រូវទៅ និងលេខទូរស័ព្ទ ដែលយើងអាចទាក់ទងទៅកាន់លោកអ្នកបាន ។ បើមានការរងរបួស ដែលតំរូវអោយមានការព្យាបាល គឺបុគ្គលិក YMCA Camp Oakes និ ង /ឬ បុគ្គលិក LBUSD នឹងព្យាយាមទាក់ទងទៅកាន់លោកអ្នក ប៉ុន្តែ បើទាក់ទងទៅអាណាព្យាបាលមិនបានទេ គឺការយល់ព្រមនឹងផ្តល់ទៅកាន់វេជ្ជបណ្ឌិតដែលបានទទួលការជ្រើសរើស ដោយបុគ្គលិក YMCA Camp Oakes និង/ឬបុគ្គលិក LBUSD ដើម្បីធ្វើការព្យាបាលសិស្សតាមការចាំបាច់និងសមរម្យតាមការវិនិច្ឆ័យរបស់វេជ្ជបណ្ឌិត ។

## **ការធានារ៉ាប់រងផ្នែកសុខភាព**

ក្នុងនាមជាមាតាបិតា ឬ អាណាព្យាបាល គឺលោកអ្នកទទួលខុសត្រូវមកលើថ្លៃព្យាបាល ដែលកើតឡើងដោយសារការរងរបួស ឬ ជំងឺ នៅពេលសិស្សរបស់លោកអ្នកចូលរួមកម្មវិធីសិក្សានេះ ។ ចំពោះគ្រួសារ ដែលគ្មានការធានារ៉ាប់រងផ្នែកសុខភាព គឺយើងស្នើសុំអោយបើកចូលពិនិត្យនៅតាម www.CoveredCA.com ហើយចំពោះគ្រួសារ ដែលចង់ធ្វើការជ្រើសរើសយកការធានារ៉ាប់រងផ្នែកគ្រោះថ្នាក់សំរាប់សិស្ស ដោយចេញថ្លៃចំណាយ ដោយមាតាបិតាផ្ទាល់ គឺគួរអានបន្ថែមអំពីគោលគារណ៍ច្បាប់របស់ LBUSD សំរាប់មាតាបិតា និងសិស្ស ។ ខ្ញុំយល់ថា មណ្ឌលអប់រំ គ្មានការធានារ៉ាប់រងអ្វីមកលើថ្លៃព្យាបាល ឬ ថ្លៃចំណាយលើមន្ទីរពេទ្យនោះទេ និងម្លោះហើយ ការបង់ថ្លៃចំណាយទាំងអស់ សំរាប់ការព្យាបាលបែបនោះ គឺជាការទទួលខុសត្រូវចំពោះខ្ញុំទាំងស្រុង ។ សូមធ្វើការបញ្ជាក់ដោយផ្តល់ជាព័ត៌មានអោយបានច្បាស់លាស់ អំពីការធានារ៉ាប់រងផ្នែកសុខភាពរបស់លោកអ្នកនៅលើក្រដាស Health History Form ។

## **ការបាត់បង់និងការស្វែងរករបស់ប្រើប្រាស់**

Camp Oakes គឺជាកន្លែងផ្តល់ឱកាសសំរាប់សិស្សថ្នាក់ទី ប្រាំ រៀនទទួលខុសត្រូវចំពោះរបស់ប្រើប្រាស់របស់ពួកគេ ។ សូមពិគ្រោះជាមួយសិស្សរបស់លោកអ្នកអំពីការចេះទទួលខុសត្រូវ និងការថែរក្សានូវរបស់ប្រើប្រាស់របស់ពួកគេ ។ LBUSD និង YMCA មិនទទួលខុសត្រូវទេចំពោះរបស់ប្រើប្រាស់ដែលបាត់បង់ ឬ ត្រូវបានមនុស្សផ្សេងលួចយក ។ **កុំផ្ញើរបស់មានតម្លៃ** ទៅជាមួយសិស្សរបស់លោកអ្នកអោយសោះ ។

របស់ប្រើប្រាស់ទាំងឡាយណាដែលបាត់ហើយត្រូវបានរកឃើញដោយបុគ្គលិក គឺនឹងយកទៅប្រគល់ជូននាយកគ្រប់គ្រងកម្មវិធី ។ របស់ប្រើប្រាស់ទាំងឡាយណា ដែលមិនបានទាមទារយកវិញអោយទាន់ចុងសប្តាហ៍ គឺនឹងផ្ញើបញ្ជូនទៅកាន់នាយកគ្រប់គ្រង LBUSD ហើយនឹងមានការព្យាយាមគ្រប់យ៉ាងសំរាប់បញ្ជូនត្រឡប់ទៅកាន់ម្ចាស់ដើមវិញ ។ សាលារៀននីមួយៗនឹងទទួលការស្នើសុំអោយជួយបញ្ជូនរបស់បាត់បង់ទៅកាន់ម្ចាស់ដើមវិញ ហើយបើរបស់បាត់បង់គ្មានឃើញការទាមទារមកវិញពីម្ចាស់ដើមនោះទេក្នុងរយៈពេល 2 សប្តាហ៍ នោះវានឹងយកទៅចែកប្រគល់អង្គការមនុស្សធម៌ ។

## **សេចក្តីរំពឹងអំពីវិន័យ/ការប្រកាន់ខ្ជាប់នូវអាកប្បកិរិយាត្រឹមត្រូវ**

សិស្សទាំងអស់នឹងតំរូវអោយគោរពតាមវិន័យរបស់ LBUSD វិន័យរបស់សាលារៀនរៀងៗខ្លួន និងវិន័យរបស់ YMCA Camp Oakes ចំពោះអាកប្បកិរិយា និងសុវត្ថិភាព សមស្របច្បាប់អប់រំលេខ Ed. Code 48900 ។ ដើម្បីរក្សានូវសុវត្ថិភាព និងសន្តិសុខអោយបានប្រសើរ គឺសិស្សនឹងចូលរួមពិគ្រោះ និងរៀបចំបង្កើតជាវិន័យសំរាប់ប្រើក្នុងកន្លែងស្នាក់នៅ ។ គ្រូបង្រៀន LBUSD និងបុគ្គលិក YMCA Camp Oakes នឹងលើកកំពស់អោយមានអាកប្បកិរិយាល្អតាមការបង្ហាញជាគំរូអំពីអាកប្បកិរិយាល្អៗ និងវិធីបច្ចេកទេសផ្សេងៗដែលសមរម្យទៅតាមវ័យកុមារ ។ វិន័យច្បាស់លាស់ដែលអនុវត្តក្នុងកម្មវិធីសិក្សាផ្នែកខាងក្រៅនឹងចែករំលែកទៅកាន់សិស្ស នៅពេលសិស្សទៅដល់កន្លែង ។ វិន័យដ៏សំខាន់ជាងគេ គឺ៖1) **រក្សានូវសុវត្ថិភាពគ្រប់ពេល** និ ង 2) **ទទួលការសប្បាយរីករាយ**! គោលការណ៍នៃកម្មវិធីសិក្សាផ្នែកខាងក្រៅដែលទ្រទ្រង់វិន័យទាំងអស់នេះ គឺនៅជាប់ជាមួយមនុស្សធំម្នាក់ និងសិស្សជាដៃគូរបស់អ្នកអោយបានគ្រប់ពេល បង្ហាញនូវការគោរពចំពោះមនុស្សគ្រប់រូបនៅតាមគ្រប់កន្លែងអោយបានគ្រប់ពេលទាំងអស់ (នេះគឺរាប់បញ្ចូលទាំងឥវ៉ាន់របស់មនុស្សដទៃ មតិយឃើញរបស់ពួកគេ ធម្មជាតិ សត្វព្រៃ ។ល។) ។

បញ្ហាផ្នែកអាកប្បកិរិយា ដែលមិនអាចតំរូវបានតាមសេចក្តីរំពឹងមកលើអាកប្បកិរិយា គឺនឹងបញ្ជូនអោយទៅទទួលការអប់រំណែនាំ ដើម្បីលើកកំពស់អោយមានអាកប្បកិរិយាល្អ ការដោះស្រាយ និងការធ្វើទំនាក់ទំនងជាមួយគូរកនមិត្ត តាមរយៈជំនាញក្នុងការទំនាក់ទំនងគ្នា ដើម្បីបង្កើននូវជំរៅទឹកចិត្តសំរាប់កុមារ និងអោយប្រាកដថា សិស្សទាំងអស់នឹងបានទទួលនូវបទពិសោធន៍ល្អ ។ បើសិស្សបង្ហាញបញ្ហាផ្នែកអាកប្បកិរិយាមិនសមរម្យ គឺនឹងមានចាត់វិធានការដូចតទៅនេះ៖

***ជួបប្រជុំជាមួយសិស្ស*** *- ពិគ្រោះអំពីវិន័យ មូលហេតុអំពីការប្រើវិន័យ និងការជួយសិស្សអោយគិតមើលឡើងវិញអំពីផលប៉ះពាល់ដែលបង្ករដោយអំពើរបស់ពួកគេ ។*

***ការជញ្ជឹងគិតដោយសិស្ស*** *- គឺអ្នកដឹកនាំឬបុគ្គលិកក្នុងកន្លែងស្នាក់នៅនឹងពិគ្រោះជាមួយសិស្សអំពីបញ្ហាផ្នែកអាកប្បកិរិយានិងជំរុញពួកគេអោយធ្វើការជញ្ជឹងគិតអំពីអំពើរបស់ពួកគេ និងណែនាំសិស្សអោយបែរមកប្រកាន់យកអាកប្បកិរិយាល្អឡើងវិញ។*

***ការណែនាំឡើងវិញ*** *- ជួយគាំទ្រសិស្សអោយធ្វើការផ្តោតយកចិត្តទុកដាក់មកលើអាកប្បកិរិយាត្រឹមត្រូវ ដោយទម្លាក់ចោលនូវអាកប្បកិរិយាមិនសមរម្យ ។*

***កាន់ចិត្តអោយត្រជាក់*** *- បុគ្គលិកនឹងទុកពេលអោយកុមារជញ្ជឹងគិតអំពីអាកប្បកិរិយារបស់ពួកគេ ឬ គ្រាន់តែទុកពេលអោយទទួល "ការធ្វើចិត្តអោយត្រជាក់" ទំរាំតែស្ថានការធូរស្បើយ ដែលអាចធ្វើការពិគ្រោះជាមួយកុមារបាន ។*

***ធ្វើការកែប្រែ*** *- បុគ្គលិកនឹងជួយគាំទ្រអោយកុមារចេះធ្វើការសុំទោស និងធ្វើអោយស្ថានការកែប្រែ ឬ បែរត្រឡប់ទៅដូចដើមវិញ បើអាចធ្វើបាន ។*

***ជួបប្រជុំជាមួយមាតាបិតា*** *- បុគ្គលិកនឹងប្រើមធ្យោបាយគ្រប់យ៉ាងសំរាប់ធ្វើការដោះស្រាយអំពីបញ្ហាផ្នែកអាកប្បកិរិយារបស់សិស្សនៅកន្លែងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។ មាតាបិតានៃសិស្ស ដែលបង្ហាញការខ្វះខាតក្នុងការឆ្លើយតប ឬ ការទទួលខុសត្រូវ គឺប្រហែលជានឹងបានទទួលការទាក់ទងតាមរយៈទូរស័ព្ទជាមួយបុគ្គលិក ដើម្បីធ្វើការដោះស្រាយអំពីបញ្ហាផ្នែកអាកប្បកិរិយា ។*

***ទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន*** *- ចំពោះសិស្ស ដែលមិនអាចគោរពតាមវិន័យបាន ឬ ធ្វើអោយមានការប៉ះពាល់មិនល្អដល់បទពិសោធន៍ទៅកាន់សិស្សដទៃ គឺប្រហែលនឹងបាត់បង់សិទ្ធិ ឬ ការប្រើប្រាស់នូវឧបករណ៍មួយរយៈពេល ។ បើសិស្សនៅតែបន្តមានបញ្ហាក្នុងការគោរពវិន័យនិងអាកប្បកិរិយាយដែលត្រូវរំពឹងទុកដូចមានចែងដូចខាងក្រោមនេះ គឺពួកគេនឹងប្រហែលបាត់បង់សិទ្ធិក្នុងការចូលរួមជាបន្តទៀត និងត្រូវបញ្ជូនអោយត្រឡប់ទៅផ្ទះវិញ ។ មាតាបិតានឹងទទួលខុសត្រូវក្នុងការទៅដកយកសិស្សរបស់ខ្លួនត្រឡប់ទៅផ្ទះវិញពីកន្លែងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។*

## ការរំលោភសិទ្ធិកុមារ

បុគ្គលិក LBUSD និងបុគ្គលិក Camp Oakes YMCA ទាំងអស់ត្រូវបានកំណត់តាមច្បាប់ ដើម្បីរាយការណ៍អំពីអំពើសង្ស័យចំពោះការរំលោភសិទ្ធិកុមារ (រាប់ទាំងផ្នែករូបកាយ ផ្លូវចិត្ត ពាក្យសំដី និង/ឬ ការធ្វេសប្រហែស) ទៅកាន់អាជ្ញាធរតាមការសមរម្យជាបន្ទាន់ ។

Hi-Hill
at YMCA Camp Oakes
LBUSD

# បញ្ជីត្រួតពិនិត្យសំរាប់សិស្ស មុននឹងចេញដំណើរ

## រៀបចំទុកជាមុន

______ជំរុញលើកទឹកចិត្តមាតាបិតារបស់អ្នកអោយឆ្លើយបំពេញនូវព័ត៌មានទាំងអស់តាមរយៈ អនឡាញ ជាពិសេស ទាក់ទងផ្នែកប្រវត្តិសុខភាព និងការយល់ព្រម ។

______ឃ្លាំមើលសុខភាពរបស់សិស្សជារៀងរាល់ថ្ងៃ មុននឹងដល់ពេលចេញដំណើរ ។ សិស្សនឹងមិនអាចចូលរួមបានទេ បើមានបញ្ហាសុខភាព ដែលមិនស្របលក្ខណតំរូវរបស់ កម្មវិធីសិក្សាផ្នែកខាងក្រៅ ។

## ថ្ងៃអ្នកចេញដំណើរ

______នាំយកវ៉ាលី ប្រដាប់គេង និងរបស់ប្រើប្រាស់ផ្សេងៗទៀតរបស់អ្នកមកជាមួយ ដោយមានឈ្មោះរបស់សិស្សសរសរនៅពីលើអោយច្បាស់លាស់ ។

______ថ្នាំពេទ្យត្រូវរៀបដាក់ដាច់ដោយឡែក - **មិនមែនដាក់ជាមយយតវ៉ាននោះទេ** និងមានឈ្មោះរបស់សិស្សសរសេរបង្ហាញអោយច្បាស់លាស់ ។

______**ស្លៀកខោជើងវែង** (មិនមែនខោឃើតជើងវែងនោះទេ) និងពាក់ស្បែកជើងសមលក្ខណៈងាយស្រួលសំរាប់ ដើរ/ដើរឆ្ងាយឬឡើងទួល ។

# បញ្ជីត្រួតពិនិត្យសំរាប់រៀបខ្ចប់តវ៉ាន់

*ត្រូវប្រាកដថា ឈ្មោះរបស់អ្នក និងឈ្មោះសាលារៀនគឺសរសេរច្បាស់មែនទែននៅលើវ៉ាលីទាំងអស់ ដើម្បីងាយមើលឃើញ ។*

សិស្សអាចយកវាលីទៅបានចំនួន ៣ ៖

1) កាតាបស្ពាយតូច (មានខ្សែចងភ្ជាប់) សំរាប់ស្ពាយជាមួយនៅតាមឡាន ប៊ីស
2) វ៉ាលី សំរាប់ដាក់សំលៀកបំពាក់
3) កំរាលក្រាស់សំរាប់ក្រាលគេង

*សិស្សគួរតែអាចកាន់យក វ៉ាលីទាំង 3 ចេញពីឡាន ប៊ីស ទៅកន្លែងស្នាក់នៅបានក្នុងពេលតែម្តង*

**វ៉ាលី #1: កាតាបស្ពាយសាលារៀន** - កាន់កាតាបនេះទុកនៅជាមួយអ្នកនៅពេលជិះឡាន ប៊ីស
របស់នេះនឹងនាំឡើងចូលឡាន ប៊ីស ជាមួយអ្នកសំរាប់អ្នកប្រើបាន ក្រោយពេលទទួលទានអាហារល្ងាចរួច នៅពេលទៅដល់កន្លែងនៅថ្ងៃដំបូង ។

- ដបទឹក ដែលមានឈ្មោះរបស់អ្នក
- ស្រោមដៃ
- អាវរងា
- អាវយឺតដៃវែងក្រាស់
- កូនពិល
- ស្រោមជើងបន្ថែម
- អាវយឺតក្រាស់/អាវភ្លៀង (ការពារខ្យល់/មិនសើមទទឹក)
- មួកពាក់សំរាប់អោយកក់ក្តៅ

**វ៉ាលី #2: កំរាលសំរាប់ក្រាលគេង** - អាចយកប្រើបាន បន្ទាប់ពីពេលទទួលទានអាហារល្ងាចរួច
នេះអាចយកប្រើបាន បន្ទាប់ពីពេលទទួលទានអាហារល្ងាចរួច ។ ខ្នើយមួយ និងកំរាលគេងមួយដែលខ្ចប់ក្នុង ថង់ប្លាស្ទិកធំ (ការពារពេលមានអាកាសធាតុប្រែ) ។ សរសេរឈ្មោះរបស់អ្នក និងសាលារៀននៅពីលើ ។ កំរាល និងភួយក្រាស់ អាចប្រើ ជាកំរាលក្រាលគេងបាន ។

**វ៉ាលី #3:** វ៉ា លី /កាបូបយួរធំ - អាចយកប្រើបាន បន្ទាប់ពីពេលទទួលទានអាហារល្ងាចរួច
ស្នើសុំអោយរៀបដាក់របស់ប្រើប្រាស់នៅថង់ប្លាស្ទិក ziplock ឬ ថង់សំរាមធំ ក្រែងលោមានភ្លៀង ។ របស់ប្រើប្រាស់ទាំងអស់ ដែលមិនបានរាយបង្ហាញនៅផ្នែកខាងលើ គឺគួរដាក់ទៅជាមួយវ៉ាលី ឬ កាបូបយួរធំ ហើយអ្នកនឹងមិនអាចយកប្រើបានទេ លុះត្រាតែដល់ពេលទទួលទានអាហារល្ងាចរួចរាល់សិន ។

**របស់ប្រើប្រាស់ចាំបាច់៖**

_______ប្រេង/ក្រែមលាបបបូរមាត់

_______ស្បែកជើង ស្បែកជើងពាក់អោយជិតម្រាមជើង ឬ ប៊ូតសំរាប់ដើរភ្នំ

_______ខោជើងវែង (មិនមែនខោខ្លី ឬ ខោយឺតជើងវែងទេ) (ចំនួន 3)

_______អាវយឺតក្រាស់ (1)

_______អាវយឺតដៃខ្លី (5)

_______ស្រោមដៃពាក់អោយកក់ក្តៅ

_______មួក ប៊ីនី (1)

_______ស្រោមជើង (ជាតិកប្បាស) (6-8 គូ)

_______ថ្នាំ និង ច្រាសដុសធ្មេញ

_______ស្និតសិតសក់

_______ប្រេងការពារស្បែកក្រោមកំដៅថ្ងៃ

_______ស្បែកជើងពាក់ងូតទឹក

_______អាវយឺតដៃវែងក្រាស់ (2)

_______សំលៀកបំពាក់គេងពេលយប់

_______អាវដៃវែង (2)

_______ខោអាវទ្រនាប់ (8)

_______ថ្នាំបំបាត់ការធុំភ្លៀក

_______មួកមានហាម (1)

_______សាប៊ូដុះខ្លួន និងសាប៊ូកក់សក់

_______កន្សែងនិងក្រណាតជូតសំអាតខ្លួន

**របស់ផ្សេងទៀត ដែលអាចយកទៅបាន៖**

__________ថង់ដាក់សំលៀកបំពាក់សំរាប់បោក (សំលៀកបំពាក់ក្រខ្វក់)

__________ម៉ាស៊ីនថតរូប (ចង់បាន ប្រើហើយ ចោល)

__________វ៉ែនតាពាក់ការពារកំដៅថ្ងៃ

_______សៀវភៅអាន

_________តុក្កតាសត្វទន់ៗសំរាប់គេងអោប

*នៅពេលខ្លះ មានធាតុត្រជាក់ខ្លាំងណាស់នៅឯកន្លែងកម្មវិធីសិក្សាផ្នែកខាងក្រៅ ។ ដូច្នេះ យើងសូមជំរុញអោយអ្នកយកចិត្តទុកដាក់ខ្ចប់យកសំលៀកបំពាក់ស្តើងៗសំរាប់ពាក់ច្រើនជាន់ ជាជាងសំលៀកបំពាក់ក្រាស់ៗតែមួយមុខប៉ុណ្ណោះ ។ នេះជាមធ្យោបាយអោយអ្នកងាយដោះមួយចេញនៅពេលក្តៅ និងពាក់មួយជាន់ថែមទៀតនៅពេលរងារ ដើម្បីជៀសវាងនូវការត្អូញត្អែថា "ខ្ញុំក្តៅណាស់ដោយពាក់ពាក់អាវក្រាស់ពេក ប៉ុន្តែខ្ញុំរងារនៅពេលណាខ្ញុំអាវចេញ" ។*

*សូមអោយប្រាកដក្នុងចិត្តថា នៅពេលរៀបចំសំលៀកបំពាក់ គឺអ្នកអាចពាក់អាវដល់ទៅ 5 ជាន់លើខ្លួនរបស់អ្នក (អាវយឺតដៃវែង អាវយឺតដៃខ្លី អាវយឺតដៃវែងក្រាស់ អាវរងា និងអាវពាក់ការពារទឹកភ្លៀង) ហើយស្លៀកខោ 2 ជាន់ នៅផ្នែកខាងក្រោមនៃខ្លួនរបស់អ្នក (ខោវែងទ្រនាប់ក្នុង និង ខោវែងក្រាស់) ។*

*សូមចំណាំថា មានភាពខុសគ្នាច្រើនណាស់រវាង អាវរងា ឬ អាវការពារទឹក ដោយមូលហេតុថា មួយ គឺការពារមែនទែនមិនអោយទទឹកសើមខ្លួន (waterproof) ហើយមួយទៀត គឺការពារដែរ (water resistant) ប៉ុន្តែ មិនអាចធានាបានយូរទេ ។ បើអ្នកនឹងដាក់អាវរងាភ្ជាប់ទៅជាមួយសិស្សរបស់អ្នកជា water resistant គឺទឹកនឹងឆាប់ងាយទទឹកសើមខ្លួន ហើយសិស្សនឹងរងានិងទទឹកសើមខ្លួន!*

***សូមកុំភ្លេចសរសេរឈ្មោះរបស់អ្នក និងឈ្មោះសាលារៀននៅលើរបស់ប្រើប្រាស់សព្វយ៉ាង ។**

**LBUSD និង YMCA មិនទទួលខុសត្រូវទេជាដាច់ខាតចំពោះរបស់ប្រើប្រាស់ ដែលបាត់បង់ ឬ ត្រូវបានមនុស្សផ្សេងលួចយក ។ ទោះជាយ៉ាងនេះក្តី ក៏យើងនឹងព្យាយាមបញ្ជូនរបស់ប្រើប្រាស់ដែលបានបាត់បង់ទៅទាំងប៉ុន្មាន ត្រឡប់ទៅអោយម្ចាស់ដើមវិញ នៅពេលណាអាចរកឃើញមកវិញ* ។**